ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៩៣/០៩-វីវីរីច

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: ម៉ារ សំបូរណា

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: រ៉ែន ពៅ

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លៈ

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន វីវីរីច គិចស្តាយ អិលធីឌី

អាសយដ្ឋាន : ភូមិព្រៃកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០១៦ ៧០៦ ១៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក តាំង ស៊ុនហេង | ប្រធានរដ្ឋបាល ក្រុមហ៊ុន វីវីរីច |
| ២- លោក លឹម វេញ | ប្រធានរដ្ឋបាល ក្រុមហ៊ុន ហ្វាំង សុាំង |
| ៣- លោក តុប ស៊ីថា | ជំនួយការនាយកក្រុមហ៊ុន ហ្វាំង សុាំង |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន វីវីរីច

អាសយដ្ឋាន : ផ្ទះលេខ ៦ សេ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៨២ ៦៩៣ លេខទូរសារ : គ្មាន

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក អ៊ុំ វិសាល | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក ភិន សុភា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន |
| ៣- លោក ចឹក ប៊ុនសាន | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ |
| ៤- លោក ម៉ូវ វុធ | សកម្មជន |
| ៥- លោក វ៉ាន់ ថៃ | សកម្មជន |
| ៦- លោក ហ៊ុំ ប៊ុន | សកម្មជន |
| ៧- លោក ព្រាប ណារិទ្ធិ | សកម្មជន |
| ៨- លោក ហៀក គីមសៀក | សកម្មជន |
| ៩- លោក នឿន វណ្ណា | សកម្មជន |
| ១០- លោក សឿន សុខន | សកម្មជន |
| ១១- លោក វណ្ណ ស៊ីថន | សកម្មជន |
| ១២- លោក ឃាង វុធថា | សកម្មជន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើឱ្យក្រុមហ៊ុនទទួលយកកម្មករផ្នែកអ៊ុត ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ ឱ្យចូលធ្វើការវិញ។ ភាគីក្រុមហ៊ុនមិនឯកភាព ព្រោះកម្មករដែលបានបញ្ឈប់ពីការងារ ជាកម្មកររបស់ក្រុមហ៊ុន ហ្វាំង ស៊ាំង។

២- ស្នើឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសតំណាងកម្មករឱ្យបានឆាប់រហ័ស។ ភាគីក្រុមហ៊ុន នឹងរៀបចំនៅខែ១២ ឆ្នាំ២០១០។

៣- ស្នើឱ្យក្រុមហ៊ុនចេញតំលៃឡូត៍ក្រោយពេលកម្មករធ្វើបានរយៈពេលពី ០៣ ទៅ ០៧ ថ្ងៃ។ ភាគី ក្រុមហ៊ុនមិនអាចចេញតំលៃឡូត៍ក្រោយពេលកម្មករធ្វើបានរយៈពេលពី ០៣ ទៅ ០៧ ថ្ងៃ គឺក្រុមហ៊ុនរៀបចំចេញតំលៃឡូត៍ជារៀងរាល់ចុងខែនីមួយៗ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៤២៤/០៩ កប/កណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកាត់ដេរកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីជំលោះស្រាយវិវាទការងាររួមរបស់កម្មករនិយោជិតនៃរោងចក្រ វីវីវីច។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះនឹងគ្នាចំនួន ២ ចំណុច លើការទាមទារទាំងអស់ចំនួន ០៥ ចំណុច ហើយនៅសល់ចំនួន ០៣ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និង ភាគីកម្មករនិយោជិតមកសវនាការ និង ធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទទាំង ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចវិវាទទី២ (ភាគីទាំងពីរព្រមព្រៀងគ្នា) និងចំណុចវិវាទទី៣ (ភាគីកម្មករនិយោជិតបានដកការទាមទារ) ។ ដូច្នេះ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទទី១ ប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

### ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន វីវើរីច ផ្ទេរសិទ្ធិជូន លោក តាំង ស៊ុនហេង ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីវើរីច តិចស្តាយ អិលធីឌី ចុះបញ្ជិកាលេខ ០០១/០៧ ក.ប.វ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧។

៣- លក្ខន្តិកៈក្រុមហ៊ុន វីវើរីច តិចស្តាយ អិលធីឌី ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦។

៤- កិច្ចព្រមព្រៀងខ្ចីកម្មករ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩។

៥- សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើសំណុំរឿង លេខ ៧១/០៨-វីវើរីច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨។

៦- ពាក្យសុំចូលបំរើការងារ កិច្ចសន្យាការងារ និង សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាការងារមានកំណត់ថិរវេលា របស់កម្មករចំនួន ៤០ នាក់។

៧- តារាងប្រាក់ឈ្នួលប្រចាំខែកក្កដា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន ហ្វាំងស៊ាំង អិលធីឌី។

៨- កិច្ចព្រមព្រៀងខ្ចីកម្មករ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩។

៩- លិខិតផ្ទេរសិទ្ធិរបស់ប្រធានក្រុមហ៊ុន ហ្វាំងស៊ាំង ផ្ទេរសិទ្ធិជូន លោក លឹម វេញ ជាប្រធានរដ្ឋបាល និង លោក គុប ស៊ីថា ដើម្បីចូលដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០០៩។

១០- ប័ណ្ណប៉ាតង់ (របបម៉ៅការ) ឆ្នាំ២០០៩ របស់ក្រុមហ៊ុន ហ្វាំង ស៊ាំង លេខ ០០៤៦៣ អពដ/សខ/មជ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩។

១១- លិខិតរបស់ក្រុមហ៊ុន ហ្វាំងស៊ាំង ស្តីពីការជំទាស់ទៅនឹងខ្លឹមសារនៃសារណាសង្ខេបរបស់សហជីព C.CAWDU លើសំណុំរឿងលេខ ១៩៣/០៩ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- សារណាសង្ខេបលើសំណុំរឿងលេខ ១៩៣/០៩ នៃរោងចក្រ វីវើរីច លេខ ១២៣/០៩ ស.ក.ប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ វីវើរីច ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៣- បង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករប្រចាំខែកក្កដា ឆ្នាំ២០០៩ នៃក្រុមហ៊ុន ហ្វាំងស៊ាំង អិលធីឌី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីវើរីច លេខ ៤២៤/០៩ ក.ប/កណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វីវើរីច ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧៩៤ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុន វីវើរីច ទទួលយកកម្មករនិយោជិតផ្នែកអ៊ុត ដែលក្រុមហ៊ុន បញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ**

- កម្មករនិយោជិតចំនួន ៤០ នាក់ បានចុះកិច្ចសន្យារយៈពេលខ្លី (២០ថ្ងៃ) ជាមួយក្រុមហ៊ុន ហ្វាំង ស៊ាំង ដោយចាប់ផ្តើមកិច្ចសន្យាពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ ហើយបានបន្តចំនួន ៣ ដង និងចុងក្រោយបញ្ចប់ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ នេះ។ កម្មករនិយោជិតទាំងនេះ បានទៅធ្វើការនៅក្រុមហ៊ុន វីវើរីច (ផ្នែកអ៊ុត) តាមរយៈកិច្ចសន្យាខ្ចីកម្មករ(កិច្ចសន្យាផ្គត់ផ្គង់កម្មករ) រវាងក្រុមហ៊ុន ហ្វាំង ស៊ាំង និងក្រុមហ៊ុនវីវើរីច។ ប៉ុន្តែក្រុមហ៊ុន ហ្វាំង ស៊ាំង មិនបានភ្ជាប់បញ្ជីឈ្មោះកម្មករនិយោជិត ដែលត្រូវបញ្ជូនទៅក្រុមហ៊ុន វីវើរីច ទេ ហើយក្រុមហ៊ុន វីវើរីច ក៏មិនបានជូនដំណឹងទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទងនឹងការខ្ចីកម្មករនិយោជិតពីក្រុមហ៊ុន ហ្វាំង ស៊ាំង ដែរ ដោយគ្រាន់តែផ្ញើចម្លងកិច្ចសន្យាកម្មករនិយោជិតទាំងនោះ ប៉ុណ្ណោះ ។
- កម្មករនិយោជិតទាំងនេះ ត្រូវក្រុមហ៊ុនបញ្ឈប់ ដោយមិនបន្តកិច្ចសន្យារយៈពេលខ្លី (២០ថ្ងៃ) នេះទៀតឡើយ។ ក្រុមហ៊ុន ហ្វាំង ស៊ាំង អះអាងថា នៅក្នុងរោងចក្រ វីវើរីច មិនមានតម្រូវការកម្មករនិយោជិតនៅក្នុងផ្នែកអ៊ុតនេះទៀតទេ។ ដូច្នេះ ក្រុមហ៊ុន វីវើរីច មិនបន្តខ្ចីកម្មករ ពីក្រុមហ៊ុន ហ្វាំង

ស៊ាំង ទៀតឡើយ ហើយក្រុមហ៊ុន ហ្វាំង ស៊ាំង ក៏មិនបន្តផ្គត់ផ្គង់កម្មករផ្នែកនេះ ឱ្យក្រុមហ៊ុន វីវើរីច ទៀតដែរ។ មកដល់ថ្ងៃសវនាការ នៅសល់តែកម្មករនិយោជិតតែចំនួន ២៤ នាក់ ប៉ុណ្ណោះ ដែលទាមទារឱ្យក្រុមហ៊ុន វីវើរីច ទទួលចូលធ្វើការវិញ។

- ភាគីក្រុមហ៊ុន វីវើរីច មិនអាចទទួលយកកម្មករនិយោជិតឱ្យចូលធ្វើការវិញទេ ហើយសុំឱ្យកម្មករនិយោជិត គោរពតាមកិច្ចសន្យារវាងពួកគេ និងក្រុមហ៊ុន ហ្វាំង ស៊ាំង ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា ពួកគាត់បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ហ្វាំង ស៊ាំង មែន ប៉ុន្តែ ពុំបានដឹងថា ក្រុមហ៊ុននេះមានទីតាំងនៅឯណាទេ។ ក្រុមហ៊ុន ហ្វាំង ស៊ាំង ជ្រើសរើសពួកគេនៅមុខក្រុមហ៊ុន វីវើរីច ហើយឱ្យពួកគេធ្វើការនៅក្រុមហ៊ុន វីវើរីច ដោយបើកប្រាក់ឈ្នួល ពីក្រុមហ៊ុន វីវើរីច ប៉ុន្តែ ប្រើប្រាស់កាតក្រុមហ៊ុន ហ្វាំង ស៊ាំង។ បង្កាន់ដៃបើកប្រាក់របស់កម្មករទាំងអស់នេះ មានមួយចំនួនរបស់ក្រុមហ៊ុន វីវើរីច និងមួយចំនួនទៀតរបស់ក្រុមហ៊ុន ហ្វាំង ស៊ាំង ។
- ប្រធានរដ្ឋបាលនៃក្រុមហ៊ុន ហ្វាំង ស៊ាំង បានបញ្ជាក់នៅក្នុងសវនាការថា ក្រុមហ៊ុន ហ្វាំង ស៊ាំង មានទីតាំងនៅផ្សារដីហុយ (ឬស្សីកែវ) ប៉ុន្តែ ក្នុងប័ណ្ណប៉ាតង់ បានបញ្ជាក់អាសយដ្ឋានរបស់សិប្បកម្មនេះស្ថិតនៅក្នុងខណ្ឌមានជ័យ។ ក្រុមហ៊ុននេះ មិនមានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬ លក្ខន្តិកៈក្រុមហ៊ុនទេ ព្រោះជាសិប្បកម្មខ្នាតតូច ប៉ុន្តែមានប័ណ្ណប៉ាតង់។ ប្រធានរដ្ឋបាលបានបន្ថែមទៀតថា ដោយសារតែថៅកែក្រុមហ៊ុន ហ្វាំង ស៊ាំង និងថៅកែក្រុមហ៊ុន វីវើរីច ជាមិត្តភក្តិនឹងគ្នា នៅពេលដែលក្រុមហ៊ុន វីវើរីច ត្រូវការកម្មករបន្ទាន់ ក្រុមហ៊ុន ហ្វាំង ស៊ាំង ក៏យល់ព្រមចុះកិច្ចសន្យាផ្គត់ផ្គង់កម្មករឱ្យក្រុមហ៊ុន វីវើរីច ស្របពេលជាមួយគ្នាដែលក្រុមហ៊ុន ហ្វាំង ស៊ាំង ក៏គ្មានការឱ្យកម្មករនិយោជិតធ្វើផង ហើយដោយសារតែទទួលបានកំរៃជើងសារ សំរាប់ការស្វែងរកផងនោះ ក៏សិប្បកម្មនេះយល់ព្រមផ្គត់ផ្គង់កម្មករបន្ទាន់ និងរយៈពេលខ្លីៗបែបនេះ ដល់ក្រុមហ៊ុន វីវើរីច។ ប្រធានរដ្ឋបាលបានបញ្ជាក់ថា កម្មករទាំងអស់នេះ បើកប្រាក់ឈ្នួលពីគណនីរបស់ខ្លួន ប៉ុន្តែ ពេលខ្លះក្រុមហ៊ុន ហ្វាំង ស៊ាំង រៀបចំមិនទាន់ ក៏បានស្នើសុំឱ្យក្រុមហ៊ុន វីវើរីច ជួយបើកជូនជំនួស បន្ទាប់មកទើបធ្វើការទូទាត់បញ្ជីជាមួយក្រុមហ៊ុន វីវើរីច ជាក្រោយ ដើម្បីកុំឱ្យយឺតយ៉ាវដល់ការបើកប្រាក់ឈ្នួលជូនដល់កម្មករ ។
- កម្មករនិយោជិតបានជំទាស់នឹងការលើកឡើងនេះ ដោយបញ្ជាក់ថា ពួកគាត់មិនមែនជាកម្មករចាស់របស់ក្រុមហ៊ុន ហ្វាំង ស៊ាំង និងមិនដែលធ្វើការនៅក្រុមហ៊ុន ហ្វាំង ស៊ាំង ទេ ប៉ុន្តែជាកម្មករ ដែលក្រុមហ៊ុន ហ្វាំង ស៊ាំង រើសនៅក្រុមហ៊ុន វីវើរីច ហើយឱ្យធ្វើការនៅក្រុមហ៊ុន វីវើរីច។
- លោក អ៊ុំ វិសាល បានលើកឡើងថា នេះគ្រាន់ជាការរៀបចំរបស់ក្រុមហ៊ុន វីវើរីច តែប៉ុណ្ណោះ គឺ

ក្រុមហ៊ុនរៀបចំឱ្យមានភ្នាក់ងាររបស់ខ្លួន ដើម្បីជ្រើសរើសកម្មករនិយោជិតរយៈពេលខ្លី ព្រោះក្រុមហ៊ុនមានកិច្ចព្រមព្រៀងជាមួយស៊ីខៅខូ ស្តីពីការមិនចុះកិច្ចសន្យារយៈពេលខ្លីៗ។ ម្យ៉ាងវិញទៀត កិច្ចសន្យាដែលកម្មករនិយោជិតចុះនោះ មិនអាចយកជាការបានទេ ពីព្រោះមិនមានឈ្មោះក្រុមហ៊ុនច្បាស់លាស់ទេ (ទំព័រទី១) ហើយពួកគេក៏មិនបានមើលកិច្ចសន្យានោះដែរ គឺគ្រាន់តែបានផ្តិតមេដៃតែប៉ុណ្ណោះ។

- ក្រុមហ៊ុន វីវើវីច មិនទទួលស្គាល់កិច្ចព្រមព្រៀងដែលសហជីពស៊ីខៅខូ បានលើកឡើងនោះទេ ។ កន្លងមក ក្រុមហ៊ុនក៏មានជួលកម្មករនិយោជិតរយៈពេលខ្លីៗ ហើយសព្វថ្ងៃក៏នៅមានកម្មករនិយោជិតដែលមានកិច្ចសន្យារយៈពេលខ្លីៗចំនួនតិចតួចដែរ។
- ក្រុមហ៊ុន ហ្វាំង ស៊ាំង ទទួលស្គាល់ថា មិនបានឱ្យកិច្ចសន្យានោះទៅកម្មករនិយោជិតមែន ប៉ុន្តែ ប្រធានរដ្ឋបាល ដែលជាអ្នករើសកម្មករនិយោជិតទាំងនោះ បានអានកិច្ចសន្យាឱ្យកម្មករនិយោជិតទាំងនោះស្តាប់។
- ក្រុមហ៊ុន វីវើវីច បញ្ជាក់ថា ការដែលខ្លួនឱ្យក្រុមហ៊ុន ហ្វាំង ស៊ាំង ជួយរើសកម្មករនិយោជិតឱ្យ គឺអាស្រ័យទៅលើកំណើនការងារ ដែលក្រុមហ៊ុនត្រូវការកម្មករនិយោជិតបន្ទាន់ ហើយជាកំណើនរយៈពេលខ្លីៗម្តងម្កាល។ ក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនជួលកម្មករនិយោជិតជាប់លាប់ផ្នែកអ៊ុត ប្រហែល ១៨០នាក់ ហើយកម្មករនិយោជិតរយៈពេលខ្លីចំនួន៤០នាក់(បញ្ចប់អស់ហើយ)។ បច្ចុប្បន្ន ក៏នៅមានកម្មករនិយោជិតរបស់ក្រុមហ៊ុន ហ្វាំង ស៊ាំង ប្រហែល១០០នាក់ កំពុងធ្វើការនៅក្រុមហ៊ុន វីវើវីច ដែរ តែបម្រើការនៅផ្នែកផ្សេងៗ លើកលែងតែផ្នែកអ៊ុត ហើយកម្មករនិយោជិតខ្លះ មានអតីតភាពរហូតដល់ ២ ឆ្នាំ ទៅហើយទៀតផង។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលនូវឯកសារមួយចំនួនពីភាគីនិយោជក នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ដូចជា កិច្ចសន្យាការងាររបស់កម្មករនិយោជិត និងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន វីវើវីច និងក្រុមហ៊ុន ហ្វាំង ស៊ាំង លើការខ្ចីកម្មករនិយោជិត និងឯកសារពីភាគីកម្មករនិយោជិត នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩។
- នៅក្នុងសារណារបស់កម្មករនិយោជិតបានផ្តល់ឈ្មោះកម្មករដែលធ្វើការទាមទារមានចំនួន ៣៣ នាក់ ហើយ ក្រុមហ៊ុន វីវើវីច មិនបានជំទាស់ទៅនឹងចំនួនកម្មករដែលធ្វើការទាមទារនេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្មត់យកចំនួនកម្មករនិយោជិតដើមបណ្តឹងមានចំនួន ៣៣ នាក់ ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុន វីវើរីច ទទួលយកកម្មករនិយោជិតផ្នែកអ៊ុត ដែលក្រុមហ៊ុន បញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ**

ក្នុងករណីនេះ សហជីពបានទាមទារឱ្យក្រុមហ៊ុន វីវើរីច ទទួលយកកម្មករនិយោជិតចំនួន ៣៣ នាក់ ដូចមានបញ្ជីឈ្មោះរៀបរាប់នៅក្នុងសារណារបស់សហជីពចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានកិច្ចសន្យាការងារ ជាមួយសិប្បកម្ម ហ្វាំង ស៊ាំង បានចូលធ្វើការនៅផ្នែកអ៊ុតរបស់ក្រុមហ៊ុន វីវើរីច វិញ ខណៈពេលដែលកិច្ចសន្យាការងាររបស់កម្មករទាំង ៣៣ នាក់ នោះ ត្រូវផុតកំណត់ត្រឹមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩។ ក្រុមហ៊ុន វីវើរីច ជំទាស់ថា កម្មករនិយោជិតទាំង ៣៣ នាក់ នោះ មិនមែនជាកម្មករនិយោជិតរបស់ ក្រុមហ៊ុន វីវើរីច ទេ ពោលគឺ ក្រុមហ៊ុន វីវើរីច មានកិច្ចព្រមព្រៀង ខ្ចីកម្មករនិយោជិតពីក្រុមហ៊ុន ហ្វាំង ស៊ាំង។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោមៈ

- តើមានកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន វីវើរីច និង ក្រុមហ៊ុន ហ្វាំង ស៊ាំង លើការខ្ចីកម្មករនិយោជិតមែន ឬទេ?
- តើកម្មករនិយោជិតទាំង ៣៣ នាក់ មានទំនាក់ទំនងបែបណាជាមួយក្រុមហ៊ុន វីវើរីច?
- តើក្រុមហ៊ុន វីវើរីច ត្រូវទទួលខុសត្រូវឱ្យកម្មករនិយោជិតទាំងអស់ចំនួន ៣៣ នាក់ ចូលធ្វើការវិញ ឬ ទេ?

**ក. តើមានកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន វីវើរីច និង ក្រុមហ៊ុន ហ្វាំង ស៊ាំង លើការខ្ចីកម្មករនិយោជិតមែន ឬទេ?**

យោងតាមអង្គហេតុ ក្រុមហ៊ុន វីវើរីច បញ្ជាក់ថា ក្រុមហ៊ុន គឺមានកិច្ចព្រមព្រៀងខ្ចីកម្មករនិយោជិតពី ក្រុមហ៊ុន ហ្វាំង ស៊ាំង។

មាត្រា ៤៥ នៃច្បាប់ស្តីពីការងារបានចែងថា *"ការិយការី គឺជាអ្នកទទួលការពីសហគ្រិន ជ្រើសរើសកម្មករ ហត្ថពលិកដោយខ្លួនឯងតាមតម្រូវការ ដើម្បីប្រតិបត្តិការងារ ឬ ផ្តល់សេវាណាមួយដោយគិតថ្លៃសរុប។ កិច្ចសន្យានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ"*។

ក្នុងសំណុំរឿងនេះ សិប្បកម្ម ហ្វាំង ស៊ាំង មានសកម្មភាពអាជីវកម្ម ផ្តល់សេវាបោះពុម្ពលើសំលៀកបំពាក់ ដែលមានទីតាំងស្ថិតនៅភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ សិប្បកម្មនេះ បានបង់ប៉ាតង់ជាបន្តបន្ទាប់ តាមរបបម៉ៅការ រហូតឆ្នាំ២០០៩ នេះ តាមរយៈបណ្ណប៉ាតង់ លេខ ០០៤៦៣ អពជ/សខ/មជ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ក្នុងទ្រង់ទ្រាយអាជីវកម្មជាសហគ្រាសឯកត្តជន (ឬឯកបុគ្គល) ដែលមានអ្នកគ្រប់គ្រងសហគ្រាសឈ្មោះ ប៉ាន ជិម៉ុង សញ្ជាតិខ្មែរ ថ្ងៃខែឆ្នាំកំណើត ១៧-ឧសភា-១៩៦៩។ តាមរយៈបណ្ណប៉ាតង់នេះ

បញ្ជាក់ថា សហគ្រាសនេះត្រូវបានទទួលស្គាល់ដោយអង្គភាពសាខាពន្ធដារ ខណ្ឌមានជ័យ នៃអគ្គនាយកដ្ឋានពន្ធដារ ថា ជាសហគ្រាសឯកបុគ្គល ធ្វើសកម្មភាពអាជីវកម្មសេវាបោះពុម្ពលើសំលៀកបំពាក់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា តាមកិច្ចព្រមព្រៀងខ្ចីកម្មករនិយោជិតពីក្រុមហ៊ុន ហ្វាំង ស៊ាំង គឺ សិប្បកម្ម ហ្វាំង ស៊ាំង ដើរតួនាទីជាការិយភារីឱ្យក្រុមហ៊ុន វីវើរីច ក្នុងការផ្គត់ផ្គង់កម្មករនិយោជិត ដែលមានកិច្ចសន្យារយៈពេលខ្លី ក្នុងលក្ខណៈបន្ទាន់តាមកំណើនសង្វាក់ផលិតកម្ម។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញមានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងខ្ចីកម្មករ រវាងក្រុមហ៊ុន វីវើរីច និងសិប្បកម្ម ហ្វាំង ស៊ាំង នេះ មានខ្លឹមសារផ្ទុយនឹងស្មារតីនៃច្បាប់កិច្ចសន្យា និងខ្លឹមសារនៃបញ្ញត្តិផ្នែកទី ៨ នៃជំពូក២ នៃច្បាប់ស្តីពីការងារ ទាក់ទងនឹងការិយភារីឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់ថា ពិតជាមានកិច្ចសន្យាខ្ចីកម្មករនិយោជិត ដែលធ្វើឡើង ដោយ ក្រុមហ៊ុន វីវើរីច និង ក្រុមហ៊ុន ហ្វាំង ស៊ាំង មែន។

**ខ. តើកម្មករនិយោជិតទាំង ៣៣ នាក់ មានទំនាក់ទំនងបែបណាជាមួយក្រុមហ៊ុន វីវើរីច?**

មាត្រា ៦៥ នៃច្បាប់ស្តីពីការងារចែងថា " *កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និង និយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។* "

យោងតាមអង្គហេតុ កម្មករនិយោជិតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ហ្វាំង ស៊ាំង តាមរយៈខ្លឹមសារនៃកិច្ចសន្យា ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មវត្ថុនៃកិច្ចសន្យាដែលបានធ្វើឡើង រវាងសិប្បកម្ម ហ្វាំង ស៊ាំង និងកម្មករទាំង ៣៣ នាក់ នោះ គឺកិច្ចសន្យាការងារជាកម្មករចល័ត។ នៅក្នុងសវនាការ ភាគីកម្មករបានទទួលស្គាល់ថា ពួកគេបានស្តាប់ការអាន និងផ្តិតមេដៃយល់ព្រមលើកិច្ចសន្យាការងារទាំងនោះ ជាមួយប្រធានរដ្ឋបាលសិប្បកម្ម ហ្វាំង ស៊ាំង និងថា ខ្លួនជាកម្មកររបស់ក្រុមហ៊ុន ហ្វាំង ស៊ាំង ដែលរយៈពេលនៃកិច្ចសន្យានោះ គឺ ២០ ថ្ងៃ ហើយត្រូវបន្ត ២០ ថ្ងៃទៀត រៀងរាល់ពេលមានការងារ ដោយមានប្រាក់ឈ្នួល ៥០ ដុល្លារអាមេរិក ក្នុងមួយខែ ស្របតាមប្រាក់ឈ្នួលអប្បបរិមា ដែលកំណត់ដោយក្រសួងការងារ។ មួយវិញទៀត កម្មករនិយោជិតទទួលស្គាល់ថា ខ្លួនត្រូវធ្វើការនៅក្រុមហ៊ុន វីវើរីច ទៀតផង។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចុះកិច្ចសន្យារវាងកម្មករនិយោជិត និង ក្រុមហ៊ុន ហ្វាំង ស៊ាំង គឺធ្វើឡើងដោយស្របច្បាប់។

យោងតាមអង្គហេតុ និងការបកស្រាយខាងលើ គឺកម្មករនិយោជិតទាំង ៣៣ នាក់នោះ ជាកម្មករនិយោជិតចល័តរបស់ក្រុមហ៊ុន ហ្វាំង ស៊ាំង ដែលក្រុមហ៊ុន ហ្វាំង ស៊ាំង ជាការិយភារី ដែលផ្តល់កម្មករនិយោជិត

THE ARBITRATION COUNCIL

ទាំង ៣៣ នាក់នោះ មកក្រុមហ៊ុន វីវើរីច ដើម្បីធ្វើការ ។ ហេតុនេះ កម្មករនិយោជិតទាំង ៣៣ នាក់នោះ មិនមែន ជាកម្មករនិយោជិតរបស់ក្រុមហ៊ុន វីវើរីច ឡើយ ។

**គ. តើក្រុមហ៊ុន វីវើរីច ត្រូវទទួលខុសត្រូវឱ្យកម្មករនិយោជិតទាំងអស់ចំនួន ៣៣ នាក់ ចូលធ្វើការវិញ ឬទេ?**

*មាត្រា ៤៧ នៃច្បាប់ស្តីពីការងារចែងថា "ការិយភារីត្រូវគោរពបទប្បញ្ញត្តិនៃច្បាប់ការងារ ដូចគ្នានឹងនិយោជកធម្មតា ហើយក្នុងករណីនេះ ត្រូវទទួលខុសត្រូវដូចនិយោជកដែរ" ។*

មាត្រា ៤៨ នៃច្បាប់ស្តីពីការងារចែងថា "*ក្នុងករណីការិយភារីគ្មានប្រាក់ចេញឱ្យ ឬក្នុងករណីដែលការិយភារី មិនបានបំពេញកាតព្វកិច្ចសព្វគ្រប់សហគ្រិន ឬនាយកសហគ្រាស ត្រូវតែយកខ្លួនជំនួសជននោះ ដើម្បីបំពេញកាតព្វកិច្ចចំពោះកម្មករនិយោជិត*" ។

តាមន័យនៃមាត្រាទាំងពីរខាងលើ ក្រុមហ៊ុន វីវើរីច អាចនឹងត្រូវទទួលខុសត្រូវដោយផ្ទាល់ ចំពោះកម្មករនិយោជិតទាំង ៣៣ នាក់ ទាក់ទងនឹងការអនុវត្តកិច្ចសន្យាការងារ ប្រសិនជាសិប្បកម្ម ហ្វាំង ស៊ាំង មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះកម្មករនិយោជិត ។

ប៉ុន្តែ នៅក្នុងសំណុំរឿងនេះ សិប្បកម្ម ហ្វាំង ស៊ាំង បានចេញមុខនៅក្នុងសវនាការអះអាងទទួលខុសត្រូវចំពោះកម្មករនិយោជិតដើមបណ្តឹងទាំងអស់នេះថា ជាកម្មកររបស់ខ្លួន ហើយរាល់ការខកខានមិនបានបំពេញកាតព្វកិច្ចណាមួយនោះ ខ្លួនជាអ្នកទទួលខុសត្រូវ។ ប្រធានរដ្ឋបាល ហ្វាំង ស៊ាំង បានអះអាងថា សិប្បកម្ម ហ្វាំង ស៊ាំង បានបំពេញរាល់កាតព្វកិច្ចដែលមានចែងក្នុងច្បាប់ និងកិច្ចសន្យាការងារជូនដល់កម្មករនិយោជិតទាំង ៣៣ នាក់នេះ រួចហើយ ប៉ុន្តែ ចំពោះការទាមទារឱ្យបន្តកិច្ចសន្យាការងារ គឺសិប្បកម្ម ហ្វាំង ស៊ាំង មិនអាចទទួលបានឡើយ ព្រោះក្រុមហ៊ុន វីវើរីច បានផ្អាកការខ្ចី ឬផ្គត់ផ្គង់កម្មករពីសិប្បកម្មរបស់ខ្លួន ព្រោះមូលហេតុ គ្មានការងារឱ្យធ្វើ ។ ដូចនេះ សិប្បកម្មក៏មិនអាចចុះកិច្ចសន្យាការងារបន្តជាមួយកម្មករទៀតបានឡើយ ក្នុងករណីដែលមិនមានតម្រូវការកំលាំងពលកម្មផ្នែកអ៊ុត ។

តាមការវិភាគ និងពិចារណាខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៣៣ នាក់ គឺជាកម្មករចល័តរបស់សិប្បកម្ម ហ្វាំង ស៊ាំង ដែលសិប្បកម្មនេះ ដើរតួនាទីជាការិយភារីជួយផ្គត់ផ្គង់កម្មករឱ្យក្រុមហ៊ុន វីវើរីច សំរាប់កម្មករនិយោជិតដែលមានកិច្ចសន្យាការងាររយៈពេលខ្លី១ ទៅតាមកំណើននៃសង្វាក់ផលិតកម្ម ។

ក្រុមហ៊ុន វីវើរីច មានសិទ្ធិស្របច្បាប់ក្នុងការផ្អាកការខ្ចី ឬការផ្គត់ផ្គង់កម្មករពីសិប្បកម្ម ហ្វាំង ស៊ាំង ស្របតាមតំរូវការសង្វាក់ផលិតកម្មរបស់ខ្លួន និងបញ្ញត្តិនៃកិច្ចព្រមព្រៀងខ្ចីកម្មកររវាងភាគីទាំងពីរ (វីវើរីច និង ហ្វាំង ស៊ាំង ) ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិត មិនមានមូលដ្ឋានគតិយុត្តិសមស្របឡើយ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុន វីវើរីច ទទួលយកកម្មករនិយោជិតទាំង ៣៣ នាក់ ផ្នែកអ៊ុត ដែលក្រុមហ៊ុនបញ្ឈប់ពីការងារ ឱ្យចូលធ្វើការវិញ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និង ហេតុផល ដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុន វីវើរីច ទទួលយកកម្មករនិយោជិតទាំង ៣៣ នាក់ ផ្នែកអ៊ុត ដែលក្រុមហ៊ុនបញ្ឈប់ពីការងារ ឱ្យចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ម៉ាវ សំបូរណា**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ----------------------------------------